**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួប២០ឆ្នាំនៃការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩ - ៣០ ខែមេសា ឆ្នាំ២០១៩

- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ
- សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី
- បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុង និងក្រៅប្រទេស ជាទីស្នេហា

១) ថ្ងៃនេះ កម្ពុជាប្រារព្ធព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់មួយក្នុងនយោបាយការបរទេសរបស់ខ្លួន នោះគឺការប្រារព្ធខួបគម្រប់២០ឆ្នាំនៃសមាជិកភាពរបស់ខ្លួនក្នុងអាស៊ាន។ ចាប់តាំងពីបានក្លាយជាសមាជិកអាស៊ាន នៅថ្ងៃទី៣០ ខែមេសា ១៩៩៩មក កម្ពុជាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកដទៃទៀត ក្នុងការកសាងសហគមន៍អាស៊ានមួយ ដែលផ្តោតលើប្រជាជន និងយកប្រជាជនជាស្នូល ក្នុងស្មារតីនៃភាពម្ចាស់ការ និងការទទួលខុសត្រូវរួម ។ ជាការពិត អាស៊ានបានក្លាយជាស្នូលមួយនៃនយោបាយការបរទេសរបស់កម្ពុជា ដែលអាចឆ្លុះបញ្ចាំងបានតាមរយៈការផ្សារភ្ជាប់ការអភិវឌ្ឍផ្នែកនយោបាយ សង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ទៅនឹងសមាហរណកម្មតំបន់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងខណៈដែលកម្ពុជា ប្តេជ្ញាសម្រេចនូវចក្ខុវិស័យក្នុងការក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ កម្ពុជាចាត់ទុកសហគមន៍អាស៊ានជាប្រភពនៃសន្តិភាព សន្តិសុខ និងវិបុលភាពសំរាប់ប្រជាជនខ្មែរ។

២) ចាប់តាំងពីការកកើតនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧មក អាស៊ានមាននិទានកថាប្រកបដោយសុទិដ្ឋិនិយមជាច្រើនដែលផ្តល់នូវក្តីសង្ឃឹមដល់ប្រជាជនប្រមាណ ៦៥០លាននាក់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាច្រើនរយលាននាក់ផ្សេងទៀតនៅក្រៅតំបន់អាស៊ីអាគ្នេយ៍នេះ។ មនុស្សមួយចំនួន ថែមទាំងបានចាត់ទុកអាស៊ានថាជាអព្ភូតហេតុនៃទិសបូព៌ា។ ប្រការដែលមិនអាចប្រកែកបាន គឺអង្គការ

តំបន់មួយនេះ បានលើកតម្កើងសន្តិភាព និងវិបុលភាពនៅក្នុងតំបន់មួយដែលធ្លាប់តែមានវិបត្តិ ហើយអង្គការតំបន់ផ្សេងៗទៀតបានគិតថាអាស៊ានជាស្ថាប័នតំបន់មួយ ដែលជោគជ័យ និងសំខាន់ជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងឥណ្ឌូប៉ាស៊ីហ្វិកជារួម។ អាស៊ាន ជានិមិត្តរូបនៃភាពចម្រុះ និងសន្តិសហវិជ្ជមាន ព្រោះថា ប្រទេសសមាជិកទាំងដប់ ដែលមានអរិយធម៌ វប្បធម៌ និងជំនឿខុសៗគ្នា មានស្មារតីរួមគ្នាឆ្ពោះទៅរកអត្តសញ្ញាណតែមួយ សហគមន៍តែមួយ និងជោគវាសនាតែមួយ។ ជាក់ស្តែង ភាពចម្រុះនេះ ត្រូវបានគេមើលឃើញថាគឺជាចំណុចខ្លាំងជាមូលដ្ឋានរបស់អង្គការអន្តររដ្ឋាភិបាលមួយនេះ។

៣) អាស៊ាន បានផ្តល់នូវខែលសន្តិសុខជាទីទុកចិត្តមួយ ដល់ប្រទេសសមាជិក ក្នុងការពារឯករាជ្យភាព និងអធិបតេយ្យរបស់ខ្លួន។ ការគោរពគ្នាទៅវិញទៅមក កិច្ចពិគ្រោះយោបល់គ្នាទៅវិញទៅមក ការយោគយល់គ្នាទៅវិញទៅមក និង អត្ថប្រយោជន៍រួម បានក្លាយជាបទដ្ឋាន និងចំណុចខ្លាំងនៃអភិក្រមអាស៊ាន ក្នុងការធ្វើឱ្យយន្តការសំរាប់កិច្ចសន្ទនា និងការកសាងទំនុកចិត្ត មានចីរភាព។ ភាពជោគជ័យរបស់អាស៊ាន ស្ថិតនៅលើលក្ខណៈបើកចំហ បរិយាប័ន្ន និងសម្លឹងទៅក្រៅទោះបីជា គោលការណ៍នៃការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើកុងសង់ស៊ុស ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរវាងគ្នា និងគោរពអធិបតេយ្យភាពគ្នា ជាមូលដ្ឋានគ្រឹះនៃឯកភាពរបស់អាស៊ាន ។ ការតស៊ូ និងការប្រឆាំងនឹងការជ្រៀតជ្រែកពីបរទេស បានក្លាយនិងបន្តក្លាយជាគោលការណ៍ស្នូលរបស់អាស៊ាន ដរាបណាគោលការណ៍នេះដែលជាមូលដ្ឋាននៃផលប្រយោជន៍ទៅវិញទៅមក និង នៃអត្ថប្រយោជន៍រួមរបស់អាស៊ានជាមួយដៃគូសន្ទនា ស្ថិតនៅតែជាគោលការណ៍គន្លឹះរបស់អាស៊ានក្នុងការធ្វើការជាមួយដៃគូខាងក្រៅ។ ប្រទេសកម្ពុជាចូលរួមយ៉ាងពេញទំហឹងក្នុងគោលការណ៍គ្រឹះរបស់អាស៊ាននេះ ។

៤) នៅក្នុងវិស័យសេដ្ឋកិច្ច កម្ពុជាទទួលបាននូវផលប្រយោជន៍យ៉ាងធំធេងពីការចូលជាសមាជិកនៃក្រុមគ្រួសារអាស៊ាន។ ដោយចាប់ផ្តើមពីការផ្លាស់ប្តូរសេដ្ឋកិច្ចបន្តិចបន្តួចជាមួយប្រទេសសមាជិកអាស៊ាន នាពេលបច្ចុប្បន្ន គឺជាទីផ្សារនាំចេញធំជាងគេទីបីរបស់កម្ពុជា បន្ទាប់ពីសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត បានកើនឡើងពី៤ភាគរយនៅឆ្នាំ១៩៩៩ ទៅដល់ជាង២០ភាគរយនៅឆ្នាំ២០១៨។ អាស៊ានក៏ជាវិនិយោគិនមួយក្នុងចំណោមវិនិយោគិនធំជាងគេនៅកម្ពុជា។ នៅឆ្នាំ២០១៦ វិនិយោគទុនពីអាស៊ានមានប្រមាណជាង១៧ភាគរយនៃវិនិយោគទុនដោយផ្ទាល់ពីបរទេសនៅកម្ពុជា។ ពាក់ព័ន្ធនឹងភ្ញៀវទេសចរណ៍បរទេសនៅកម្ពុជា អាស៊ានស្ថិតក្នុងលំដាប់ខ្ពស់ទីបី។

៥) ជាច្រើនឆ្នាំកន្លងទៅនេះ អាស៊ានបានពង្រឹង និងពង្រីក កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេស និងអង្គការក្រៅតំបន់នានា។ អាស៊ានមិនបានបង្កការគំរាមកំហែងដល់ប្រទេសណាមួយ

ហើយថែមទាំងមិនបានចាប់បង្ខំភាគីដទៃឲ្យទទួលយកទស្សនទានរបស់ខ្លួនឡើយ។ មជ្ឈភាពអាស៊ាន ស្ថិតនៅជាគោលការណ៍ស្នូលរបស់អាស៊ានក្នុងការចូលរួមជាមួយដៃគូខាងក្រៅ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ និងវាយតម្លៃខ្ពស់ដោយដៃគូសន្ទនារបស់ខ្លួន ដោយសារគោលការណ៍នេះមានឥទ្ធិពលនៅក្នុងការទូតពហុភាគីតំបន់។ ចំណុចខ្លាំងនៃអាស៊ាន បានមកពីឯកភាពតំបន់ផង និងពីការគាំទ្រពីដៃគូសន្ទនាទាំងអស់របស់អាស៊ានផង។ ក្នុងនាមជាសមាជិកចុងក្រោយរបស់អាស៊ាន កម្ពុជាទទួលបានផលប្រយោជន៍យ៉ាងធំធេងពីយន្តការសមាហរណកម្មតំបន់មួយនេះ ដូចជាទីផ្សារដ៏ធំ លំហូរវិនិយោគទុនផ្ទាល់ពីបរទេស និងសកម្មភាពទេសចរណ៍ ក៏ដូចជា ការផ្ទេរនូវជំនាញ និងចំណេះធ្វើ។ ជាកិច្ចឆ្លើយតប កម្ពុជាប្តេជ្ញាដើរតួនាទីយ៉ាងសកម្មក្នុងការសម្រេចឲ្យបាននូវគោលដៅដ៏ថ្លៃថ្លាដូចមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន។

៦) ក្នុងបរិបទនៃការកើនឡើងនូវជម្លោះភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជាក្នុងតំបន់ ដោយសារការប្រកួតប្រជែងរវាងមហាអំណាច ការស្ថិតនៅរួបរួមគ្នារបស់កម្ពុជានិងប្រទេសសមាជិកអាស៊ានដទៃទៀត កាន់តែមានសារៈសំខាន់ ក្នុងការឆ្លើយតបរួមគ្នាទៅនឹងហានិភ័យ និងបញ្ហាប្រឈមចំពោះមុខ។ កម្ពុជានៅតែបន្តផ្តល់សារៈសំខាន់យ៉ាងធំធេងដល់មជ្ឈភាពអាស៊ាន នៅក្នុងការវិវត្តនៃនិម្មាបនកម្មតំបន់។ ដោយរួបរួមគ្នាជាប្លុកមួយ អាស៊ានអាចទប់ទល់នឹងផលប៉ះពាល់ជាអវិជ្ជមាន ដែលបង្កឡើងដោយ ការផ្លាស់ប្តូរមិនចេះឈប់ឈរនៃភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជា នៅក្នុងសកលលោក។ អាស៊ានអាចកសាងសណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើវិធានច្បាប់ ដែលបើកចំហ មានតម្លាភាព បរិយាប័ន្ន និងធានាថាគ្រប់ប្រទេសទាំងអស់នឹងទទួលបានផលប្រយោជន៍ស្មើគ្នាពីសមាហរណកម្ម និងអភិក្រមកសាងសហគមន៍។

៧) ជាការពិត អាស៊ាន មិនមែនជាអង្គការល្អឥតខ្ចោះទេ ។ អាស៊ាន នៅមានចំនុចខ្សោយនិងបញ្ហាប្រឈមខាងស្ថាប័នជាច្រើន ដែលត្រូវដោះស្រាយ។ ក៏ប៉ុន្តែ ប្រសិនបើគ្មានអាស៊ាន តំបន់អាស៊ីអាគ្នេយ៍ទាំងមូល ក៏មិនអាចសម្រេចបាននូវសន្តិភាព និងវិបុលភាពដូចសព្វថ្ងៃនោះដែរ។ គ្មានទេស្ថាប័នតំបន់ផ្សេងទៀតដែលល្អប្រសើរជាងអាស៊ាន នៅក្នុងតំបន់។ ដូចនេះ យើងត្រូវបន្តធ្វើឲ្យអាស៊ានមានសារៈសំខាន់ក្នុងប្រព័ន្ធអន្តរជាតិ។ យើងត្រូវការភាពជាអ្នកដឹកនាំដែលមោះមុត រឹងមាំ នៅក្នុងអាស៊ានដើម្បីឲ្យអង្គការតំបន់នេះ អាចហែលឆ្លងដំណាក់កាលខាងមុខដែលពោរពេញទៅដោយបញ្ហាប្រឈម ភាពមិនច្បាស់ប្រជា និងភាពគ្រោះថ្នាក់។ ក្នុងបរិការណ៍នេះ កម្ពុជាប្តេជ្ញាបន្តធ្វើការរួមគ្នាជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ដើម្បីធានាថាតំបន់អាស៊ាននៅតែមានសន្តិភាព សុវត្ថិភាព និងវិបុលសុខ ហើយអាស៊ាន ស្ថិតនៅជាអង្គការតំបន់មួយដែលបន្តមានសារៈសំខាន់ចំពោះប្រជាជាតិរបស់ខ្លួន។

សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី

៨) ឆ្ពោះទៅអនាគតខាងមុខ កម្ពុជានឹងបន្តដើរតួនាទីបុរេសកម្ម និងប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាថា អាស៊ាននៅតែជាចំនុចស្នូលនៃនិម្មាបនកម្មតំបន់ តាមរយៈការប្រកាន់ខ្ជាប់នូវស្មារតីអាស៊ាន និងអាស៊ានមួយដែលឈរលើវិធានច្បាប់។ សុខដុមនីយកម្មរវាងអត្ថប្រយោជន៍ជាតិ និងផលប្រយោជន៍រួមរបស់អាស៊ាន ដោយព្យាយាមរក្សា និងតុល្យភាពសមស្របជាមួយដៃគូខាងក្រៅ និងដោយខិតខំពង្រីកបន្ថែមការតភ្ជាប់ដើម្បីសម្រេចឲ្យបាននូវ សហគមន៍អាស៊ានដែលយកប្រជាជនជាស្នូល និងជាលក្ខណៈពិសេសនៃយុទ្ធសាស្ត្រសមាហរណកម្មតំបន់របស់កម្ពុជា។ ដោយមានការលើកទឹកចិត្តដោយសារភាពជោគជ័យនៃការធ្វើជាប្រធានអាស៊ាន នៅឆ្នាំ២០០២ និង២០១២ កម្ពុជាទន្ទឹងរង់ចាំដោយក្តីរំភើបសោមនស្សរីករាយ ក្នុងការធ្វើជាប្រធានផ្លាស់វេនអាស៊ាន នៅឆ្នាំ២០២២។

៩) នៅប៉ុន្មានឆ្នាំខាងមុខនេះ កម្ពុជា និងតំបន់អាស៊ានទាំងមូល នឹងជួបប្រទះនូវការផ្លាស់ប្តូរយ៉ាងសំខាន់ៗ ជាពិសេស នៅក្នុងវិស័យនវានុវត្តន៍ឌីជីថល និងបច្ចេកវិទ្យា និងវិស័យការតភ្ជាប់។ បដិវត្តន៍ឧស្សាហកម្មទីបួន នឹងពន្លឿនល្បឿននៃបញ្ឈប់ និង ការផ្លាស់ទីកន្លែងនៃមូលដ្ឋានផលិត នៅខណៈពេលនៃការប្រែប្រួលពីបែបបទប្រពៃណីនៃខ្សែសង្វាក់ផលិតកម្មសកល ទៅជាប្រព័ន្ធផលិតមួយដែលមានលក្ខណៈឌីជីថល និងទំនើបជាងមុន។ បណ្តាញទីក្រុងឆ្លាតវៃអាស៊ាន និងគំនិតផ្តួចផ្តើមផ្សេងៗទៀតស្តីពី អាស៊ានឌីជីថល នឹងទទួលបានការគាំទ្រខ្លាំងជាងមុន។ កម្ពុជាត្រូវតែបង្កើននូវកិច្ចខិតខំប្រឹងប្រែងក្នុងការចាប់យកការប្រែប្រួលទាំងនេះ ដោយបន្តធ្វើការវិនិយោគបន្ថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធទន់និងរឹង ដើម្បីទាញយកប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មទីបួន ។

១០) នេះជាតថភាពបច្ចុប្បន្ន ដែលយើងកំពុងឆ្លងកាត់ ដំណាក់កាលនៃការផ្លាស់ប្តូរតុល្យភាពអំណាចសកលលោក ដែលមានមកជាមួយនូវភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់។ បញ្ហាក្នុងតំបន់និងសកលលោក កាន់តែមានភាពស្មុគស្មាញ និងប្រទាក់ប្រឡាគ្នា ហើយគ្មានប្រទេសណាមួយ ទោះបីជាមានអំណាចខ្លាំងក្លាយ៉ាងណាក៏ដោយ អាចដោះស្រាយបញ្ហាទាំងនេះតែម្នាក់ឯង និងនៅក្នុងភាពឯកកោតែឯងបានឡើយ។ ដោយធ្វើការរួមគ្នា ប្រទេសសមាជិកអាស៊ានទាំងអស់ ត្រូវតែពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូអន្តរជាតិរបស់ខ្លួន ក្នុងអភិក្រមដ៏គ្រប់ជ្រុងជ្រោយមួយ ដើម្បីដោះស្រាយបញ្ហាប្រឈម និងក្តីកង្វល់រួមក្នុងតំបន់។ ជោគវាសនារបស់កម្ពុជា កាន់តែវេញជាឆ្លុងមួយកាន់តែខ្លាំងក្លាឡើងជាមួយនឹងជោគវាសនាអាស៊ាន។

១១) ឆ្លៀតក្នុងឱកាសនេះ ទូលបង្គំខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ជនរួមជាតិកម្ពុជាទាំងអស់ឲ្យធ្វើការសិក្សាបន្ថែមទៀតអំពីអាស៊ាន ហើយនិងស្វែងរកកាលានុវត្តភាពថែមទៀតដែលកើតចេញពីតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម។ ក្នុងឋានៈជាប្រទេសតូច កម្ពុជា មិនអាចសង្ឃឹមថារស់នៅដោយគ្មានការផ្សារភ្ជាប់ជាមួយពិភពលោកខាងក្រៅបានទេ។ ការរីកលូតលាស់ និងវិបុលភាពរបស់

ប្រជាជនកម្ពុជាទាំងអស់ អាស្រ័យជារួមលើរបៀបធ្វើការជាមួយអាស៊ាន ក្នុងការធ្វើឱ្យសមាហរណកម្មតំបន់ កាន់តែស៊ីជម្រៅ កំពុងជា ការពង្រឹងសារៈសំខាន់ និងភាពរឹងមាំរបស់ជាតិ។

ជាចុងបញ្ចប់ ទូលបង្គំខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

ថ្ងៃ៩រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**